# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៧៦ . សសរ

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង

៣៣៣✱៤៤៤

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីស្រាវជ្រាវករណីទំនាស់នៅវត្តភ្នំរាប ស្ថិតនៅភូមិស្វាយឧត្តម ឃុំពន្សាំង វត្តសុវណ្ណធម្មរាជ ស្ថិតនៅភូមិព្រៃពង្រ ឃុំពញាពន់ និង ទំនាស់ដីធ្លីរវាងលោករស់ សារិន , ហោ ម្លិះរត្ន័ និង កញ្ញា សុវណ្ណ យុទ្ធា ស្ថិតនៅភូមិព្រៃគោល ឃុំឈ្មាំង និង ភូមិព្រៃពង្រ ភូមិស្រែដូនតូច ភូមិត្រពាំងព្រាយ ឃុំពញាពន់ ស្រុកពញាឮ ខេត្តកណ្តាល ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១-តំណាងក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២-តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច | ជាអនុប្រធាន |
| ៣-តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម សំណង់ | ជា សមាជិក |
| ៤-តំណាងក្រសួងយុត្តិធម៌ | ជាសមាជិក |
| ៥-តំណាងក្រសួងធម្មការ និង សាសនា | ជាសមាជិក |
| ៦-ប្រធាននាយកដ្ឋានស្រាវជ្រាវនិង ចារកិច្ច នៃអគ្គមេបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ | ជាសមាជិក ./ |

www.pheakdeylaw.com

៧-ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង នៃអគ្គស្នងការនគរបាលជាតិ ជាសមាជិក

៨-អភិបាល ឬ អភិបាលរងខេត្តកណ្តាល ជាសមាជិក

**ប្រការ២** : គណៈកម្មការចំរុះអន្តរក្រសួងមានភារកិច្ច ៖

-ពិនិត្យស្រាវជ្រាវ និង វាយតំលៃលើអង្គហេតុនៃទំនាស់រវាងលោក រស់ សារិន និង គណៈកម្មការអាចារ្យវត្ត នៅក្នុងវត្តភ្នំរាប និង វត្តសុវណ្ណធម្មរាជ ។

-ពិនិត្យស្រាវជ្រាវ និង វាយតំលៃលើឯកសារពាក់ពន្ធ័នឹងទំនាស់ដីធ្លីចំនួន៦កន្លែង ស្ថិតនៅភូមិព្រៃគោល ឃុំឈ្វាំង និង ភូមិព្រៃពង្រ ភូមិស្រែដូនតូច ភូមិត្រពាំងក្រោយ ឃុំពញាពន់ ស្រុកពញាឮ ខេត្តកណ្តាល រវាងលោក រស់ សារិន , ហោ ម៉ូរ៉ារ័ត្ន និង ឈ្មោះ សុវណ្ណ យុទ្ធា ។

-រាយការណ៍អំពីលទ្ធផលដែលសំរេចបានតាមជំហ៊ាននីមួយៗជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និង សំរេចដាក់វិន័យរដ្ឋបាលចំពោះមន្ត្រីពាក់ពន្ធ័ និង អ្នកសមគំនិតទាំងអស់ ឬ ក្នុងករណីចាំបាច់ត្រូវកសាងសុំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីចាត់ការតាមច្បាប់ជាធរមាន ។

**ប្រការ៣** : សមាជិកគណៈកម្មការអន្តរក្រសួងត្រូវចូលរួមប្រជុំ និង ចូលរួមបំពេញភារកិច្ចតាមការអញ្ជើញ និងការណែនាំរបស់ប្រធាន ។

**ប្រការ៤** : គណៈកម្មការចំរុះអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។ ក្នុងករណីចាំបាច់ គណៈកម្មការចំរុះអន្តរក្រសួងមានសិទ្ធិប្រើប្រាស់មន្ត្រីជំនាញនានា ដើម្បីជួយក្នុងកិច្ចការស្រាវជ្រាវករណីនេះ ។

**ប្រការ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ប្រធានស្ថាប័ន អង្គភាពពាក់ពន្ធ័ទាំងអស់ ដែលមានក្នុងប្រការ១ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៧ ឆ្នាំ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ដូចប្រការ៥ "*ដើម្បីអនុវត្ត*"
-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com